# អត្ថន័យ និងប្រវត្តិនៃទិវាកុមារអន្តរជាតិ ០១ មិថុនា

ចាប់ពីឆ្នាំ១៩៥០មក ថ្ងៃទី១ មិថុនា ជារៀងរាល់ឆ្នាំត្រូវបានពិភពលោកប្រារព្ធជាទិវាកុមារអន្តរជាតិ ។

កុមារគឺជាស្រទាប់មនុស្សវ័យក្មេងបំផុត និងជាអ្នកបន្តវេនទៅអនាគត ឬជាទំពាំងស្នងឫស្សី ។ ចង់អោយឫស្សីធំធាត់រឹងមាំល្អ គេត្រូវថែទាំទំពាំងអោយរីកលូតលាស់បានល្អជាមុនសិន ។ ចង់អោយមនុស្សនាអនាគតជាពលរដ្ឋល្អ មានសមត្ថភាព មានប្រយោជន៍ដល់សង្គមជាតិ គេត្រូវបង្កើនការយកចិត្តទុកដាក់ជាពិសេសដល់កុមារ គឺតាំងពីមុន និងក្រោយពេលកុមារកើត ។

ការយកចិត្តទុកដាក់ពិសេសដល់កុមារគឺទាំងក្នុងជីវភាពជាក់ស្តែង និងទាំងផ្នែកច្បាប់ដើម្បីការពារ ថែទាំរក្សា និងបង្កលក្ខណៈអោយកុមារបានរីកលូតលាស់ល្អ និងទទួលបានការអប់រំល្អ ទទួលបានការសំរាក និងកំសាន្តសប្បាយដែលមានផលប្រយោជន៍ ។ ការយកចិត្តទុកដាក់ពិសេសចំពោះកុមារសំខាន់ទៀត គឺការការពារ និងបញ្ចៀសកុមារពីគ្រោះមហន្តរាយផ្សេងៗ ព្រោះកុមារងាយនឹងទទួលរងគ្រោះបំផុត ទាំងដោយគ្រោះធម្មជាតិ ទាំងដោយជំងឺដង្កាត់ ទាំងដោយអំពើហិង្សាពិសេសដោយសង្គ្រាមកាប់សំលាប់ ។

គោលបំណងសំខាន់នៃការប្រារព្ធទិវាកុមារអន្តរជាតិគឺសំដៅក្រើនរំលឹក និងបង្កើនការយកចិត្តទុកដាក់ពិសេសចំពោះកុមារ ។

ជិតកន្លះសតវត្សកន្លងមកនេះ ស្ថានភាពជាទូទៅរបស់កុមារត្រូវបានកែលំអ និងលើកកំពស់បានប្រសើរឡើងជាលំដាប់ ។ ប៉ុន្តែ គេនៅតែកត់សំគាល់ឃើញថា មានកុមាររាប់សិបលាននាក់នៅលើផែនដី ភាគច្រើននៅក្នុងបណ្តាប្រទេសក្រីក្រ ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅប្រទេសមានសង្គ្រាម កំពុងទទួលរងគ្រោះដោយត្រូវគេបោះបង់ចោល ដោយទុរភិក្សអត់ឃ្លាន ដោយជំងឺ ដោយអំពើហិង្សារំលោភសិទ្ធិ ដោយទារុណកម្ម និងរហូតដល់ការកាប់សំលាប់អាយុជីវិត ។

ខាងក្រោមនេះ គឺជាប្រវត្តិសង្ខេបនៃទិវាកុមារអន្តរជាតិ ១ មិថុនា ដែលពិភពលោកតែងប្រារព្ធធ្វើជារៀងរាល់ឆ្នាំ: ឧក្រិដ្ឋកម្មដ៏ឃោរឃៅព្រៃផ្សៃរបស់ពួកហ្វាស៊ីសហ៊ីត្លែរចំពោះប្រជាជន ពិសេសចំពោះកុមារនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ បានធ្វើអោយមនុស្សជាតិស្លុតរន្ធត់ ថ្កោលទោស និងចងចាំជាប់ជានិច្ច ។

គឺគ្រោះមហន្តរាយទាំងនេះហើយដែលធ្វើអោយកងកំលាំងស្នេហាសន្តិភាព និងមិត្តភាពរវាងប្រជាជាតិ រវាងមនុស្សគ្រប់ពណ៌សម្បុរ ទាំងអស់រួបរួមគ្នាក្រោកឈរឡើង ហើយធ្វើការអំពាវនាវដើម្បីធ្វើការតស៊ូប្រឆាំងរាល់ទង្វើដែលនាំអោយអន្តរាយដល់អាយុជីវិតរបស់មនុស្សជាតិ លើសពីនេះទៀត បានអំពាវនាវដល់ការរួបរួមគ្នាក្នុងមនសិការដើម្បីការពារជីវិត ការពារសន្តិភាព សន្តិសុខ និងគាំពារបីបាច់ថែរក្សាដល់កុមារលើផែនដី ។

ព្រឹត្តិការណ៍សោកនាដកម្មមួយចំនួន ត្រូវបានកត់សំគាល់គឺនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៤២ ពួកហ្វាស៊ីស-ហ៊ីត្លែរ បានសំលាប់រង្គាលប្រជាជននៅភូមិ "លីឌីស៊ែ" នៃប្រទេសឆេក ( អតីតឆេកូស្លូវ៉ាគី) ចំនួន១៩២នាក់ ហើយនៅក្នុងសួនកសិដ្ឋាន "អូរ៉ាក់" មានកុមារ ១០៥នាក់ត្រូវបានគេយកទៅសំលាប់ ។ ម្តាយរបស់កុមារត្រូវបានគេចាប់បញ្ជូនទៅជំរុំប្រមូលផ្តុំ ឯភូមិដ្ឋានត្រូវគេឆក់ប្លន់ និងដុតបំផ្លាញចោល ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៤៤ នាថ្ងៃទី១០ មិថុនា ពួកហ្វាស៊ីសអ៊ីត្លែរ

បានប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មដែលមានរូបភាពដូចនៅ "លីឌីសែរ" ជាថ្មីម្តងទៀត គឺនៅ "អ៊ូរ៉ាឌូ" ប្រទេសបារាំងដែលពេលនោះ មនុស្សប្រុសស្រី ១១០០នាក់ ក្នុងនោះមានកុមារ ២០០នាក់ ត្រូវបានគេចាក់សាំងដុតកំលោចសំលាប់ចោលទាំងរស់ ។

អំពើឃោរឃៅព្រៃផ្សៃនេះ ត្រូវបានសាធារណៈមតិទូទាំងសាកលលោក ថ្កោលទោសយ៉ាងខ្លាំងក្លាបំផុត ។
នៅឆ្នាំ ១៩៤៥ ពួកហ្វាស៊ីស-ហ៊ីត្លែរត្រូវទទួលបរាជ័យដោយកងកម្លាំងសហភាពសូវៀត និងប្រទេសសម្ព័ន្ធមិត្ត ។
សង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ ។

៤ឆ្នាំក្រោយមក នៅខែមករា ឆ្នាំ១៩៤៩ សហព័ន្ធនារីប្រជាធិបតេយ្យពិភពលោក
បានបើកសម័យប្រជុំនៅទីក្រុងមូស្គូនៃសហភាពសូវៀត ហើយបានមូលមតិគ្នាសំរេចយកថ្ងៃ "០១ មិថុនា" ជារៀងរាល់ឆ្នាំប្រារព្ធជា "ទិវាកុមារអន្តរជាតិ" ។ សេចក្តីសំរេចនេះ ត្រូវបានទទួលការឯកភាពគាំទ្រពីអង្គការអន្តរជាតិនានា មានជាអាទិ៍ អង្គការសហព័ន្ធសហជីពកម្មករពិភពលោក និងអង្គការសហព័ន្ធយុវជនប្រជាធិបតេយ្យពិភពលោកជាដើម ។

នៅខែមេសា ឆ្នាំ១៩៥២ នៅទីក្រុងវីយែន នៃប្រទេសអូទ្រីស មានបើកការប្រជុំអន្តរជាតិមួយ ក្រោមប្រធានបទ "សន្និសិទការពារកុមារ" និងនៅឆ្នាំ១៩៥៥ ស្ត្រីជាម្តាយនៅលើពិភពលោក បានធ្វើសន្និសិទបរិហាទោសចំពោះឧបាយកលសង្គ្រាម ដែលគំរាមកំហែងដល់អាយុជីវិតមនុស្ស និងកុមាររាប់លាននាក់នៅតាមប្រទេសនានា ។
សន្និសិទបានអំពាវនាវដល់មនុស្សនៅគ្រប់ទ្វីប អោយរួមកំលាំងគ្នាឡើង ហើយត្រូវធ្វើការតស៊ូជាប្រចាំ មិនសំចៃកំលាំងដើម្បីសន្តិភាព និងសន្តិសុខរឹងមាំលើពិភពលោក ដើម្បីការអភិវឌ្ឍន៍ ដើម្បីអនាគតដ៏ត្រចេះត្រចង់របស់កុមារ និងដាច់ខាតប្រឆាំងគ្រប់អំពើឧក្រិដ្ឋកម្មដូចដែលមានរូបភាពអាណោចអធម្មនៅ លីឌីសែ និងអ៊ូរ៉ាឌូ ។

ពីមួយឆ្នាំទៅមួយឆ្នាំ "ទិវាកុមារអន្តរជាតិ ០១ មិថុនា"
ត្រូវបានទទួលបានការគាំទ្រយ៉ាងទូលំទូលាយពីបណ្តាប្រទេសលើសាកលលោក ហើយសន្និសិទជាតិ និងអន្តរជាតិជាច្រើនទៀត ត្រូវបានគេប្រារព្ធដើម្បីឧទ្ទិសដល់ការយកចិត្តទុកដាក់ចំពោះកុមារ ។

ការយកចិត្តទុកដាក់ចំពោះកុមារគឺជាការធានាចំពោះអនាគតត្រចះត្រចង់គឺជាកាតព្វកិច្ចរបស់មនុស្សធំគ្រប់រូប ។

( អត្ថបទ: គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ NGOCRC)